ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៤២ ..... សហវ.ស.ស.ព

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោង បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- បានឃើញអនុក្រឹត្យ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- បានឃើញប្រកាសលេខ ២៦៩ សហវ-ប្រក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- បានឃើញប្រកាសលេខ ៣៦៩ សហវ.ប្រក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោមៈ

- ឯកឧត្តម **គង់ ម៉ារី** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ — ប្រធាន
- ឯកឧត្តម **យ៉េត វីណែល** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ — អនុប្រធាន
- ឯកឧត្តម **តាំង ខួនលី** នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ — អនុប្រធាន
- ឯកឧត្តម **សេង ស្រេង** អគ្គនាយករងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ — អនុប្រធាន
- លោកស្រី **ឈុន ដាលីន** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា — អនុប្រធាន
- លោក **យី សុខធារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល — អនុប្រធាន
- ឯកឧត្តម **ឌី សុវណ្ណា** អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ — សមាជិក
- លោក **ហង្ស ចុន្ធិកា** អគ្គនាយករងនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន — សមាជិក
- លោក **ខង្សី វិចិត្រ** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា — សមាជិក
- លោក **ឡាយ សុខឡៀង** ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានថវិកា — សមាជិក

- លោក **ហេង ស៊ីនឿន** ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានថវិកា សមាជិក
- លោក **អៀច សេដ្ឋា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
  នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- លោក **ហៃ សុខុឆ្នា** ប្រធាននាយកដ្ឋាន
  នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
- លោក **ឡាយ សុភ័ក្ត្រ** ប្រធាននាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា សមាជិក
- លោក **តាន់ ឡូ** អនុប្រធាននាយកដ្ឋាន
  នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
- លោក **សឿង ឌុត្ថារ៉ា** អនុប្រធាននាយកដ្ឋាន
  នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
- លោក **មាស សំអាន** អនុប្រធាននាយកដ្ឋាន
  នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល សមាជិក
- លោកស្រី **សេង មួយយូ** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល សមាជិកា
- លោក **អ៊ិន សាភាន** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន សមាជិក
- លោក **ទួន សុតាផល្លា** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន សមាជិក
- កញ្ញា **ជា ម៉ីភា** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន សមាជិកា
- លោក **ខ៊ែត គឹមហាយ** ប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក
- លោក **ជោត មុនីភក្តី** អនុប្រធានការិយាល័យ
  នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក
- លោក **កែម បញ្ញា** មន្ត្រីនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក។

**ប្រការ២.-**

ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងផ្តល់យោបល់លើទិដ្ឋភាពបច្ចេកទេសនិងហិរញ្ញវត្ថុលើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ឬគម្រោង/ការងារពាក់ព័ន្ធនឹងវិស័យឌីជីថល ដែលក្រសួង-ស្ថាប័នស្នើសុំថវិកាឬ

ហិរញ្ញប្បទានមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងគម្រោងដែលស្នើនិងអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពីគ្រប់ប្រភពនៃថវិកានិងហិរញ្ញប្បទាន

- ពិភាក្សា វាយតម្លៃ និងធ្វើអាទិភាវូបនីយកម្មសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ឬគម្រោង/ការងារពាក់ព័ន្ធនឹងវិស័យឌីជីថល ដើម្បីធានាប្រសិទ្ធភាពនៃចំណាយថវិកាសាធារណៈ និងអនុលោមភាពជាមួយនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- បូកសរុប ផ្តល់អនុសាសន៍ និងផ្តល់របាយការណ៍ពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ឬគម្រោង/ការងារពាក់ព័ន្ធនឹងវិស័យឌីជីថល ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងសម្រេច មុននឹងអនុញ្ញាតឱ្យដាក់ចូលក្នុងបញ្ជីនៃការផ្តល់ថវិកា, ការអនុវត្តនីតិវិធីនៃការអនុវត្តថវិកាឬការផ្តល់ហិរញ្ញប្បទាន
- បំពេញតួនាទីនិងភារកិច្ចពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់និងតាមបញ្ជារបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។ ក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់ ប្រធានក្រុមការងារអាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិកក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារឬអនុប្រធានក្រុមការងារណាមួយក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់។

**ប្រការ៤.-**

ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ អាចអញ្ជើញតំណាងអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័ននិង/ឬអង្គភាពពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងកិច្ចប្រជុំពិនិត្យនិងពិភាក្សាតាមការចាំបាច់។

**ប្រការ៥.-**

ក្រុមការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ មានលេខាធិការដ្ឋានមួយជាសេនាធិការនៅក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ត្រូវបំពេញមុខងារជាលេខាធិការ-ដ្ឋានឱ្យក្រុមការងារនេះ។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំង អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និងសាមីខ្លួនដូចមាន ចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ